**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១២ . សសរ**

# សេចក្តីសម្រេច

## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការត្រួតពិនិត្យការអនុវត្តសារាចរណែនាំរបស់ រាជរដ្ឋាភិបាលកម្ពុជាលេខ ០៦ សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ឱ្យមានប្រសិទ្ធភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីណែនាំលេខ០១ សណន ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីសកម្មភាពមជ្ឈមណ្ឌលកំសាន្ត ឬក្លឹបកំសាន្តដែលមានបំពាក់ម៉ាស៊ីនអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ
- បានឃើញសារាចរណែនាំលេខ០៦ សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការធ្វើអាជីវកម្មល្បែងកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ(ស្លុតម៉ាស៊ីន)
- យោងសេចក្តីជូនដំណឹងលេខ៦៦ សជណ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៩ របស់ ទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការត្រួតពិនិត្យការអនុវត្តសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ០៦ សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ឱ្យមានប្រសិទ្ធភាព ដែលមាន សមាសភាពដូចខាងក្រោមៈ

www.pheakdeylaw.com

| | | |
|---|---|---|
| -ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន | អគ្គស្នងការនគរបាលជាតិ | ជាប្រធាន |
| -ឯកឧត្តម គាត ឫស្សី | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| -ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ុខ ផល | អគ្គស្នងការរងនគរបាលជាតិ | ជាអនុប្រធានអចិន្ត្រៃយ៍ |
| -ឯកឧត្តម និត ចន្ថា | តំណាងក្រសួងទេសចរណ៍ | ជាសមាជិក |
| -ឯកឧត្តម ម៉ុន ថារឫទ្ធិ | តំណាងខេត្តសៀមរាប | ជាសមាជិក |
| -លោក ទើត ទែ | តំណាងសាលាក្រុងភ្នំពេញ | ជាសមាជិក |
| -តំណាងខេត្ត-ក្រុង ពាក់ព័ន្ធ | | ជាសមាជិក |

**ប្រការ២ :** គណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការត្រួតពិនិត្យការអនុវត្តសារាចរណែនាំ របស់រាជរដ្ឋាភិបាល លេខ០៦ សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ឱ្យមានប្រសិទ្ធភាព មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

១-ត្រួតពិនិត្យអាជ្ញាប័ណ្ណធ្វើអាជីវកម្មរបស់មជ្ឈមណ្ឌលកំសាន្តអេឡិចត្រូនិច និង មេកានិចគ្រប់ប្រភេទ (ស្លុតម៉ាស៊ីន)។

២-ចាត់វិធានការជំរុញឱ្យម្ចាស់មជ្ឈមណ្ឌលកំសាន្តអេឡិចត្រូនិច និង មេកានិចគ្រប់ប្រភេទ(ស្លុតម៉ាស៊ីន) បំពាក់នូវឧបករណ៍ថតរូបភាព ដើម្បីឱ្យប្រាកដថា ពុំមានពលរដ្ឋខ្មែរចូលលេងល្បែង។

៣-ពង្រឹងបន្ថែមការដាក់កំលាំងប្រចាំការរបស់ក្រសួងមហាផ្ទៃ នៅតាមបណ្តាមជ្ឈមណ្ឌលកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ(ស្លុតម៉ាស៊ីន) ដើម្បីត្រួតពិនិត្យការអនុវត្ត របស់បណ្តាមជ្ឈមណ្ឌលកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ(ស្លុតម៉ាស៊ីន)។

៤-ក្នុងករណីម្ចាស់មជ្ឈមណ្ឌល កំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ(ស្លុតម៉ាស៊ីន) ពុំអនុវត្តតាមសារាចរណែនាំលេខ០៦ សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាល គណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការត្រួតពិនិត្យការអនុវត្តសារាចរណែនាំរបស់រាជរដ្ឋាភិបាល លេខ០៦ សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ឱ្យមានប្រសិទ្ធភាព រាយការណ៍ និងសំណូមពរជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីដកហូតអាជ្ញាប័ណ្ណអាជីវកម្ម និងចាត់វិធានការផ្អាកជាបណ្តោះអាសន្ន ឬឈានដល់ការបញ្ឈប់អាជីវកម្មមជ្ឈមណ្ឌលកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ (ស្លុតម៉ាស៊ីន)។

៥-ត្រួតពិនិត្យបច្ចេកទេសល្បែង បង្ក្រាបបទល្មើស និងហាមប្រជាពលរដ្ឋខ្មែរចូលក្នុងមជ្ឈមណ្ឌលកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ(ស្លុតម៉ាស៊ីន)។

**ប្រការ៣ :** ប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការត្រួតពិនិត្យការអនុវត្តសារាចរណែនាំរបស់រាជរដ្ឋាភិបាល លេខ០៦ សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ឱ្យមានប្រសិទ្ធភាព មានសិទ្ធិបង្កើតលេខាធិការដ្ឋានចំរុះ ដើម្បីដំណើរការកិច្ចប្រតិបត្តិការធានាប្រសិទ្ធភាពនៃការអនុវត្តសារាចរលេខ០៦ សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨។


www.pheakdeylaw.com

ប្រការ៤ : រាល់លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចនេះចាត់ទុកជានិរាករណ៍។

ប្រការ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងសាមីខ្លួនដែលមានចែងក្នុងប្រការមួយ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ. ថ្ងៃទី១៧ខែ កុម្ភៈ ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>ចំលងជូន:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលាខេត្ត.ក្រុង ដែលពាក់ព័ន្ធ
- ដូចប្រការ៥
- ឯកសារ.កាលប្បវត្តិ

www.pheakdeylaw.com